**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# លិខិតរំលែកទុក្ខ

**ជូនចំពោះ**
**ឯកឧត្តម សុលី ទណ្ឌប៉ុក នាយករងសាលាតុមិន្តរដ្ឋបាល**
**និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ មានក្ដីរន្ធត់ និងសោកស្ដាយជាពន់ពេក ដោយបានទទួលដំណឹងថា **ឧបាសិកា ឈាន គីមស្រ៊ុន** ដែលត្រូវជាម្ដាយធំរបស់ **ឯកឧត្តម** បានទទួលមរណភាពកាលពីវេលាម៉ោង ៩:៤៥នាទីយប់ នៅថ្ងៃសៅរ៍ ១០កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៣ ក្នុងជន្មាយុ ៧៩ឆ្នាំ ដោយជរាពាធ។

ក្នុងឱកាសប្រកបដោយក្ដីរំជួលចិត្ត និងសមានទុក្ខដ៏ក្រៀមក្រំបំផុតនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈទាំងអស់ សូមចូលរួមសម្ដែងនូវមរណទុក្ខដ៏ក្រៀមក្រំ និងសោកស្ដាយជាទីបំផុតជាមួយ **ឯកឧត្តម** ចំពោះការបាត់បង់យ៉ាងធំធេងមិនអាចរកអ្វីមកប្រៀបបានមួយនេះ។

ខ្ញុំសូមបួងសួងជូនដួងវិញ្ញាណក្ខន្ធរបស់ឧបាសិកា **ឈាន គីមស្រ៊ុន** បានអញ្ជើញទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ** ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ។

ថ្ងៃពុធ ១៤កើត ខែ ពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រំ សុខា